បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ៣២ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

[illegible]

[illegible]

[illegible] ១៣ [illegible] ២ [illegible]

# [illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-៨-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៦៦ តែងតាំងឥស្សរជន ០២រូប ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ឯកឧត្តម ឡេង ម៉េងឡុង, ឯកឧត្តម គ្រាញ់ ជ័យលាភីតូនី ១៥៩០

២៧-៨-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៧០ តែងតាំងលោក ឆាយ អេង (ជាឧញ៉ា) ១៥៩១

៣១-៨-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦៣ លើកលែងទោសឲ្យទណ្ឌិតឈ្មោះ ចាន់ ម៉ុនធឿន ហៅ ជី ១៥៩២

៣១-៨-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦៤ តែងតាំងមន្ត្រីជាន់ខ្ពស់ នៃក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ ១៥៩២


## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


២៨-៨-១៩៩៩ -អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ១៥៩៤

៣០-៨-១៩៩៩ -អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្ដីពីការដាក់កំហិតលើវិស័យវិនិយោគមួយចំនួន ១៦៩៥

៣០-៨-១៩៩៩ -អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្ដីពីការបង្កើតសហគ្រាសសាធារណៈ ១៦០៤

៣១-៨-១៩៩៩ -អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ១៦១៤

២៤-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ១៦១៥

២៥-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្ដីពីការតែងតាំងសមាសភាពតំណាងប្រមុខរាជរដ្ឋាភិបាលធនាគារជាតិនៃកម្ពុជា ១៦១៦

២៥-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦១៧

២៥-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦១៨

២៥-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦១៩

២៦-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្ដីពីការដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍ ១៦២០

២៧-៨-១៩៩៩ -អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្ដីពីការតែងតាំងប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ ១៦២១

| | | |
|---|---|---|
| ២៧-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូ | ១៦២២ |
| ៣០-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៦២៥ |
| ៣០-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៦២៧ |
| ៣០-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្តីពីការផ្តល់មេដាយសេវាមេត្រី | ១៦២៨ |
| ៣១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៦២៩ |
| ៣១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៦៣០ |
| ៣១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៤៩៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយកនគរបាលជាតិ | ១៦៣១ |
| ៣១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥០០ អនក្រ.តត ស្តីពីការបំពាក់ឋានន្តរសក្តិនាយកនគរបាលជាតិ | ១៦៣៣ |
| ៣១-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥០១ អនក្រ.តត ស្តីពីការតែងតាំងសមាជិកបន្ថែម នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ១៦៣៤ |


### ២-សេចក្តីសម្រេច


| | | |
|---|---|---|
| ៣១-៨-១៩៩៩ | -សេចក្តីសម្រេចលេខ ៦០ សសរ. ស្តីពីការបង្កើតគណៈកម្មការធ្វើជម្រើសមន្ត្រីរាជការ និងវិភាគមុខងារ | ១៦៣៥ |
| ៣១-៨-១៩៩៩ | -សេចក្តីសម្រេចលេខ ៦១ សសរ. ស្តីពីការផ្ទេរសិទ្ធ នៃរាជរដ្ឋាភិបាល | ១៦៣៧ |


## III. ក្រុមប្រឹក្សាធម្មនុញ្ញ

### សេចក្តីសម្រេច


| | | |
|---|---|---|
| ២៥-៨-១៩៩៩ | -សេចក្តីសម្រេចលេខ ១៣ កបធ.សសរ.ត | ១៦៣៨ |


## IV. ការងារបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រី

### ១. ប្រកាស


| | | |
|---|---|---|
| ២៥-៨-១៩៩៩ | -ប្រកាសលេខ ១១៣ ប្រក.បរ ស្តីពីការលុបឈ្មោះមន្ត្រីរាជការ | ១៦៤០ |


### ២.សេចក្តីសម្រេច


| | | |
|---|---|---|
| ៣០-៨-១៩៩៩ | -សេចក្តីសម្រេចលេខ៤០ សសរ. ស្តីពីការទទួលស្គាល់លទ្ធផល នៃការប្រលងប្រជែងជ្រើសរើសសិស្ស និស្សិត ឲ្យចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ននានា | ១៦៤២ |

## ២-ក្រសួងមហាផ្ទៃ

### ប្រកាស

៣០-៨-១៩៩៩ -ប្រកាសលេខ ១០០៨ ប្រក. ស្ដីពីការតែងតាំងនាយនគរបាលជាតិ ១៦៤៧

៣០-៨-១៩៩៩ -ប្រកាសលេខ ១០០៩ សរគរ. ស្ដីពីការបង្កើតគណៈកម្មការកិច្ចការព្រំដែន ១៦៤៨

## ៣-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

### ប្រកាស

២៦-៨-១៩៩៩ -ប្រកាសលេខ ១៥៦/៩៩ កធស. ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៤៩

៣១-៨-១៩៩៩ -ប្រកាសលេខ ១៥៩/៩៩ កធស. ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៥១

៣១-៨-១៩៩៩ -ប្រកាសលេខ ១៦០/៩៩ កធស. ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៥២

## ៤-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស

៣០-៨-១៩៩៩ -ប្រកាសលេខ ៧៥៥ អយក. ស្ដីពីការប្ដូរឈ្មោះសាលាបឋមសិក្សាសួសអី
ទៅជាសាលាបឋមសិក្សា ញ៉ឹម ខណ្ណដង សួសអី ១៦៥៣

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/៦៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ១៩៩៩

**ត្រាស់បង្គាប់**

**មាត្រា ១.-** តែងតាំងឥស្សរជន ០២រូប ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានរាយនាមដូចខាងក្រោម :

១- ឯកឧត្តម **ឡេង ម៉េងឡុង** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២- ឯកឧត្តម **ក្រាញ់ ជ័យលាតីតូនី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

**មាត្រា ២.-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៧០

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ឆាយ អេង

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ឧត្តម

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ២៨ ក្រ. ចុះថ្ងៃទី ២០-៦-៩៨

**ត្រាស់បង្គាប់**

**មាត្រា ១.-** ត្រូវបានលើកលែងទោសឲ្យទណ្ឌិតឈ្មោះ **ចាន់ ម៉ឺនធឿន ហៅជី** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១៥-៦-៩៥ របស់តុលាការក្រុងភ្នំពេញ ។

**មាត្រា ២.-** ព្រះរាជក្រឹត្យនេះ មានអនុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**មាត្រា ៣.-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ឲ្យបានសម្រេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ អនុក្រឹត្យលេខ ៦២ អនក្រ .បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១.- តែងតាំងមន្ត្រីជាន់ខ្ពស់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចខាងក្រោម :

- ឯកឧត្តម **ឆូ ថុន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល
- ឯកឧត្តម **ឌុច ទនធីតូ** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- ឯកឧត្តម **អ៊ឹម ចំរុង** ជាអគ្គនាយក នៃនាយកដ្ឋានសំណង់
- ឯកឧត្តម **សេក សេដ្ឋា** ជាអគ្គនាយក នៃនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានឡាយសេចក្តីប្រកាសបង្គំថ្វាយ

សូមឡាយព្រះហស្តព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**សោម ម៉ុនធិន**

★★★

# II. រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧៩ អនក្រ.បក

### ស្តីពីការផ្ទេរឥណទាន

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកា តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១.-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៥៨លានរៀល (ហាសិបប្រាំបីលានរៀល) ពី ជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) មកជំពូក ១១ (ចំណាយការដំណើរការរដ្ឋបាលសំភារៈ និងការជួសជុលតូច) របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២.-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ទូទាត់ថ្លៃប្រេងឥន្ធនៈ ដែលខ្វះក្នុងឆ្នាំ ១៩៩៩ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៨០ អនក្រ.បក

## ស្តីពីការដាក់កំហិតលើវិស័យវិនិយោគមួយចំនួន

...

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម បឝ/នស/៩៥ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យកែតំរូវលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការ អនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩
- យោងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានប្រកាសចំពោះមុខរដ្ឋសភា នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៩

**សំរេច**

**មាត្រា ១.-** វិស័យវិនិយោគមួយចំនួនត្រូវបានហាមឃាត់ ដោយផ្អែកលើមូលដ្ឋាននៃសន្តិសុខជាតិ សុវត្ថិភាពសង្គម ឬភាពចាំបាច់នៃសេដ្ឋកិច្ចជាតិ ដូចមានចែងក្នុងបញ្ជីវេទយិតភាព សំរាប់ការហាមឃាត់ចំពោះវិស័យឧស្សាហកម្ម និងសំរាប់ការផ្តល់ប្រព្រឹត្តកម្មជាតិដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

**មាត្រា ២.-** រាល់បទបញ្ញត្តិណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

# ឧបសម្ព័ន្ធទី១

## ជាចំណែកនៃអនុក្រឹត្យ ស្តីពីការដាក់កំហិតលើវិស័យវិនិយោគមួយចំនួន

លេខ ៨០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩

បញ្ជីវេទកិតភាព សំរាប់លើកចំពោះវិស័យឧស្សាហកម្ម

| ISIC CODE | វិស័យ / ឧស្សាហកម្ម | កំណត់សំគាល់ |
|---|---|---|
| | **I. ឧស្សាហកម្មហាមឃាត់ចំពោះវិនិយោគិនជាតិ និងបរទេស** | |
| ៣៦៩៨ | ការផលិត និងការកែច្នៃផលិតផលពាក់ព័ន្ធដល់វប្បធម៌ បុរាណវត្ថុ | ផ្អែកតាមការសំរេចជាមុនពី ក្រសួងពាក់ព័ន្ធ |
| ២០២១ | ក្តារអារ.វីនេរ្យ (Veneer). ក្តារបន្ទះ, ផលិតផលដែលប្រើប្រាស់វត្ថុធាតុដើមពីឈើក្នុងស្រុក | គ្មានអាជ្ញាប័ណ្ណថ្មីត្រូវបានអនុញ្ញាតទេ |
| ២៤១១ | ផលិតកម្ម DBSA<br>-ជាតិគីមីពុលដែលប៉ះពាល់ដល់សុខភាព និងប៉ះពាល់ ដល់បរិស្ថាន<br>-ការផលិតជាតិគីមីពុល ឬការប្រើប្រាស់ធាតុពុល | -ផ្អែកតាមការសំរេចជាមុនពីក្រសួងពាក់ ព័ន្ធ<br>-ត្រូវបានហាមឃាត់ស្របតាម សន្ធិសញ្ញាអន្តរជាតិ |
| ២៤២៩ | ការផលិតសារធាតុ Psychotropic | -ត្រូវបានហាមឃាត់សំរាប់ការផលិតសារធាតុ ដែលមានឥទ្ធិពលលើសរសៃប្រសាទក្នុងតារាងទី១<br>-ផ្អែកតាមការសំរេចជាមុនពីក្រសួងសុខាភិបាលសំរាប់សារធាតុ ដែលមានឥទ្ធិពលលើសរសៃប្រសាទក្នុងតារាងទី២ និងទី៣ |
| ២៤២៩ | ការផលិត និងជួញដូរថ្នាំញៀន | ត្រូវបានហាមឃាត់ |
| ២៩២៧ | ការផលិតសព្វាវុធ និងគ្រាប់រំសេវ | នយោបាយការពារជាតិ |
| N.A | ការផលិតផាវ និងកាំជ្រួច | ផ្អែកតាមការសំរេចជាមុនពីក្រសួងពាក់ព័ន្ធ |
| N.A | ការផលិតនូវផលិតផលដែលទាក់ទងទៅនឹងកិច្ចការពារ និងសន្តិសុខ | នយោបាយការពារជាតិ |
| | **II. ឧស្សាហកម្មហាមឃាត់ចំពោះតែបរទេស-សហគ្រាសមធ្យម-តូច SME, នយោបាយជាតិ** | |
| | គ្មាន | គ្មាន |

| | | |
|---|---|---|
| III. ឧស្សាហកម្មបើកចំហរដោយមានកំហិតខ្លះ ចំពោះវិនិយោគបរទេស | | |
| ១៦០០ | ការផលិតបារី | សំរាប់តែការនាំចេញប៉ុណ្ណោះ (នាំចេញ ១០០%) |
| ១៥៥១ | សុរា (អាល់កុល) | ផ្អែកតាមសំរេចជាមុនពីក្រសួងពាក់ព័ន្ធ |
| ២២៣០ | ផលិតកម្មភាពយន្ត | ផ្អែកតាមការសំរេចជាមុនពីក្រសួងពាក់ព័ន្ធ |
| ១៣២០ | អាជីវកម្មត្បូងថ្មមានតំលៃ | ផ្អែកតាមការចូលរួមភាគហ៊ុនក្នុងស្រុក |
| ២៦៩១ | ការធ្វើឥដ្ឋពីដីឥដ្ឋ (ប្រហោង ការ៉ូ) និងក្បឿង | ផ្អែកតាមការចូលរួមភាគហ៊ុនក្នុងស្រុក |
| ១៥៣១ | ម៉ាស៊ីនកិនស្រូវ | ផ្អែកតាមការចូលរួមភាគហ៊ុនក្នុងស្រុក |
| ២០២៩ | ចម្លាក់ថ្ម និងឈើ | ផ្អែកតាមការចូលរួមភាគហ៊ុនក្នុងស្រុក |
| ១៧១១ | តម្បាញសូត្រ | ផ្អែកតាមការចូលរួមភាគហ៊ុនក្នុងស្រុក |
| IV. សេវាកម្មទាក់ទងការផលិត | | |
| ២២១០ | ការបោះពុម្ពផ្សព្វផ្សាយ | ផ្អែកតាមការពិភាក្សាជាមួយក្រសួងព័ត៌មាន និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ២២១២ | ការបោះពុម្ពផ្សាយកាសែត ទិន្នានុប្បវត្តិ និង ទស្សនាវដ្តី ដែលបោះពុម្ពផ្សាយតាមពេលកំណត់ | |
| ២២១៣ | ការបោះពុម្ពផ្សាយឧបករណ៍ថតចំលង | ភាគហ៊ុនបរទេសត្រូវកាន់កាប់មិនឲ្យលើសពី ៤៩ភាគរយ |
| ២២១៩ | ការបោះពុម្ពផ្សាយផ្សេងៗ | |
| ២២២១ | ការបោះពុម្ព | |
| ២២២២ | សកម្មភាពសេវាទាក់ទង និងការបោះពុម្ព | |
| ៩២១៣ | សកម្មភាពទូរទស្សន៍ និងវិទ្យុ | |
| IV. សេវាកម្មទាក់ទងការផលិត | | |
| | គ្មាន | គ្មាន |
| V. សេវាកម្មទាក់ទងការផលិត | | |
| | គ្មាន | គ្មាន |

★★★

## ឧបសម្ព័ន្ធទី២

## ជាចំណែកនៃអនុក្រឹត្យ ស្ដីពីការដាក់កំហិតលើវិស័យវិនិយោគមួយចំនួន

លេខ ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៩

## បញ្ជីវេទយិតភាព សំរាប់ការផ្ដល់ប្រព្រឹត្តិកម្មជាតិ

| វិធានការ | ការពិពណ៌នាពីប្រព្រឹត្តិកម្ម |
|---|---|
| កម្មសិទ្ធិដីធ្លី | ជនបរទេសមិនអាចមានសិទ្ធិកាន់កាប់ដីធ្លីបានឡើយ ។ ដីធ្លីអាចជួលបានសំរាប់រយៈពេល ៧០ឆ្នាំ និងអាចជួលបន្តទៀតបាន ។ |
| ការអនុញ្ញាតឲ្យធ្វើការងារ | រាល់វិនិយោគិនបរទេស និងអ្នកបំរើការងារជាជនជាតិបរទេស ត្រូវបានទទួលទិដ្ឋាការ និងការអនុញ្ញាតឲ្យធ្វើការងារបាន ។ |
| ការជ្រើសរើសបុគ្គលិក | វិនិយោគបរទេស ត្រូវផ្ដល់អាទិភាពចំពោះពលរដ្ឋកម្ពុជា ក្នុងការជ្រើសរើស និងជួលឲ្យធ្វើការងារ ។<br>ពួកគេមានសិទ្ធិជួលបុគ្គលិកបរទេសដែលមានជំនាញ និងជំនាញការជនជាតិបរទេស ដែលមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជា ក្នុងចំណោមប្រជារាស្ត្រខ្មែរ ។ ប៉ុន្តែពួកគេចាំបាច់ត្រូវធ្វើតាមបទដែលទាក់ទិន និងច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារ ។ |

***

## បញ្ជីលើកលែងបណ្ដោះអាសន្ន

## សំរាប់ការបើកចំហចំពោះវិស័យឧស្សាហកម្ម

===

| ISIC CODE | ផ្នែក/ឧស្សាហកម្ម | កំណត់សំគាល់ |
|---|---|---|
| | I. ឧស្សាហកម្មហាមឃាត់ចំពោះវិនិយោគិនជាតិ និងបរទេស | |
| | គ្មាន | គ្មាន |
| | II. ឧស្សាហកម្មហាមឃាត់សំរាប់តែវិនិយោគិនបរទេសប៉ុណ្ណោះ | |
| | គ្មាន | គ្មាន |

| | | | |
|---|---|---|---|
| III. ឧស្សាហកម្មបើកចំហចំពោះវិនិយោគិនក្នុងស្រុក និងបរទេស ដោយគ្មានការកំហិតខ្លះចំពោះតែវិនិយោគិនបរទេសប៉ុណ្ណោះ ៖ | | | |
| | គ្មាន | | គ្មាន |
| IV. សេវាកម្មដែលទាក់ទងការផលិត | | | |
| | គ្មាន | | គ្មាន |
| V. សេវាផ្សេងៗ | | | |
| | គ្មាន | | គ្មាន |

***

## ឧបសម្ព័ន្ធ ៤

### សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ

## Annex IV

### Psychotropic Substances

Table I
Convention 1971

1. BROLAMFETAMINE
2. CATHINONE
3. DET
4. DMA
5. DMHP
6. DMT
7. DOET
8. ETICYCLIDINE
9. (+)LYSERGIDE
10. MDMA
11. MESCALINE
12. 4 METHYLAMINOREX
13. MMDA
14. N-ETHYL-MDA
15. N-HYDROXY-MDA
16. PARAHEXYL
17. PMA
18. PSILOCINE, PSILOTSIN
19. PSILOCYBINE
20. ROLICYCLIDINE
21. STP, DOM
22. TENAMFETAMINE
23. TENOCYCLIDNE
24. TETRAHYDROCANNABINOL
25. TMA

Table II
Convention 1971

1. AMFETAMINE
2. DEXAMFETAMINE
3. FENETYLINE
4. LEVAMFETAMINE
5. MECLOQUALONE
6. METAMFETAMINE
7. METHAQUALONE
8. METHYLPHENIDATE
9. PHENCYCLIDINE
10. PHENMETRAZINE
11. METAMEFETAMINE RACEMATE
12. SECOBARBITAL

Table III
Convention 1971

1. AMOBARBITAI
2. ALLOBARBIAL
3. ALPRAZOLAM
4. AMFEPRAMONE
5. BARBITAL
6. BENZFETAMINE
7. BROMAZEPAM
8. BUPRENORPHINE
9. BUTALBITAL
10. BUTOBARBITAL
11. CATHINE
12. CAMAZEPAM
13. CHLORDIAZEPOXIDE
14. CLOBAZAM
15. CLONAZEPATE
16. CLORIAZEPATE
17. CLOTIAZEPATE
18. CLOXAZOLAM
19. CYCLOBARBITAL
20. DELORAZEPAM
21. DIAZEPAM
22. ESTAZOLAM
23. ETHCHLORVYNOL
24. ETHINAMATE
25. ETILAMFETAMINE
26. FENCAMFAMIN
27. FENPROPOREX
28. FLUDIAZEPAM
29. FLUNITRAZEPAM
30. FLURAZEPAM
31. GLUTETHIMIDE
32. HALAZEPAM
33. HALOXAZOLAM
34. KETAZOLAM
35. LEFETAMINE
36. LOFLAZEPATE ETHYL
37. LOPRAZOLAM
38. LORAZEPAM
39. LORMETAZEPAM
40. MAZINDOL
41. MEDAZEPAM
42. MEFENOREX
43. MEPROBAMATE
44. METHYLHENOBARBITAL
45. METHYPRYLON
46. MIDAZOLAM
47. NIMETAZEPAM
48. NITRAZEPAM
49. NORDAZEPAM
50. OXAZEPAM
51. 0XAZOLAM
52. PEMOLINE
53. PENTAZOCINE
54. PENTOBARBITAL
55. PHENDIMETRAZINE
56. PHENOBARBITAL
57. PHENTERMINE
58. PINAZEPAM
59. PIPRADROL
60. PRAZEPAM
61. PYROVALERONE
62. SECBUTABARBITAL
63. TEMAZEPAM
64. TETRAZEPAM
65. TRIAZOLAM
66. VINYLBITAL

★★★

# COUNTRY: CAMBODIA
# SENSITIVE LIST FOR THE OPENING UP OF INDUSTRIES

| ISIC CODE | SECTORS/INDUSTRIES | REMARKS (RESTRICTIONS/REQUIREMENTS) |
|---|---|---|
| | **I- Industries Closed to Both National and Foreign Investors** | |
| 3698 | Manufacture/processing of cultural items. | Subject to prior approval from relevant Ministries. |
| 2021 | Sawn timber, veneer, plywood, wood-based products utilizing local Page as raw materials. | No new licence will be issued. |
| 2411 | DBSA Production.<br>Toxic chemicals affecting health of community and impacting to environment.<br><br>Production of toxic chemicals or utilization of toxic agents. | -Subject to prior approval from Ministry of Health and relevant Ministries.<br>-Prohibited in accordance with an international treaty. |
| 2429 | Manufacture of psychotropic substance (see attached) | -Prohibited for the psychotropic substances listed in the schedule I. |

| | | |
|---|---|---|
| | | -Subject to prior approval from Ministry of Health for the psychotropic substances listed in schedule II & III |
| 2429 | Manufacture/processing of narcotic drugs. | Prohibited. |
| 2927 | Manufacture of weapons and ammunitions. | National defense policy. |
| N.A | Manufacturing of firecracker and fireworks. | Subject to control. |
| N.A | Manufacturing related to defense and securities. | National defenes policy. |
| **II- Industries Closed only to Foreign, i.e., SME, National Policies** | | |
| | Nil | Nil |
| **III- Industries Open with Restriction to Foreign Investors** | | |
| 1600 | Manufacture of cigarette | only for export (100% export) |
| 1551 | Alcohol. | Subject to prior approval from relevant Ministries. |
| 2230 | Movie Production. | Subject to prior approval from relevant Ministries. |
| 1320 | Exploitation of Gemstones. | Subject to local equity participation |
| 2691 | Bricks made of clay (Hollow, solid) and tile... | Subject to local equity participation |
| 1531 | Rice Mill. | Subject to local equity participation |
| 2029 | Manufacturing of wood and stone carving | Subject to local equity participation |
| 1711 | Silk weaving | Subject to local equity participation |
| **IV- Manufacturing-Related Services** | | |
| 2210 | Publishing | |
| 2212 | Publishing of newspaper, journals and periodicals. | Subject to discussion with Ministry of Information and Ministry of Cultural and Fine Art. |
| 2213 | Publishing of recorded media. | |
| 2219 | Other publishing. | Foreign equity is restricted to maximum of 49% |
| 2221 | Printing | |
| 2222 | Service activities related to printing | |
| 9213 | Radio and television activities. | |
| **V- Other** | | |
| | Nil | Nil |

TEL-SL-NT

★★★

# COUNTRY: CAMBODIA
## SENSITIVE LIST FOR THE GRANTING OF NATIONAL TREATMENT

| MEASURES | DESCRIPTION OF TREATMENT |
|---|---|
| Ownership of Land | -Foreigners can not own land. The land can be leased for 70 years, renewable |
| Work permit | All foreign investors and employees must obtain visas and work permit. |
| Recruitment of personnel | Foreign investors shall give priority to Cambodian citizen in recruiting and hiring.<br>They have the right to employ skilled foreign personnel and experts, who are not available in the Kingdom of Cambodia among the Cambodian people. But they are subject to Immigration Law and Labour Law. |

TEL-SL-NL

★★★

# COUNTRY: CAMBODIA
## TEMPRORARY EXCLUSION LIST FOR THE OPENING UP OF INDUSTRIES

| ISIC CIDE | SECTORS/INDUSTRIES | REMARKS (Restriction/ requirement) |
|---|---|---|
| **I- Industries Closed to both Foreign and National Investors** | | |
| | NIL | NIL |
| **II- Industries Closed only to Foreign Investors, i.e SME. National Policies** | | |
| | NIL | NIL |
| **III- Industries Open to Local and Foreign Investors with Restriction only Foreign Investors** | | |
| | NIL | NIL |

| IV- Manufacturing-Related Services | | |
|---|---|---|
| | NIL | NIL |
| **V- Other Services** | | |
| | NIL | NIL |

TEL-SL-NT

***

## អនុក្រឹត្យលេខ ៨១ អនក្រ.បក
## ស្តីពីការបង្កើតសហគ្រាសសាធារណៈ
## ភ្នាក់ងារកម្ពុជានាវាចរ ហៅថា កាំសាប

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/៣០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤១ អនក្រ .បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

## សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានបង្កើតសហគ្រាសសាធារណៈ ដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ឈ្មោះ **ភ្នាក់ងារកម្ពុជានាវាចរ** ហៅថា **កាំសាប** ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **កាំសាប** មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ អាគារលេខ២ និង១០៩ កាត់ព្រះវិថី តេជោ ធួន និង ស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ និងសាខាការិយាល័យនៅក្រុងព្រះសីហនុ
- **កាំសាប** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- **កាំសាប** ត្រូវស្ថិតក្រោមឥទ្ធិពលនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ព្រមទាំងគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ។

**មាត្រា ២.-** **កាំសាប** មានភារកិច្ចធ្វើអាជីវកម្ម សេវាលើការងារ :

១- ធ្វើជាតំណាងឱ្យម្ចាស់នាវា ឬអ្នកជួលនាវា ក្នុងដំណើរការចូលចេញ អាជីវកម្មនាវាសមុទ្រ ទន្លេនៅកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា និងជួយលើកកម្ពស់ទំនាក់ទំនងសេដ្ឋកិច្ចដឹកជញ្ជូននាវាសមុទ្រ ទន្លេជាមួយប្រទេសក្រៅ ។

២- ចាត់ចែងសុំច្បាប់ឱ្យនាវាចូល និងចេញពីកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- ស្នើសុំអ្នកនាំផ្លូវ និងតំណាងឱ្យនាវា ។

៤- ទាក់ទងសុំរកការលើកដាក់ ផ្ទេរ ស្តុក ទទួល ប្រគល់ រាប់ ថ្លឹង វាស់ ទំនិញក្នុងឃ្លាំង លើទីលាន ឬលើផែ និងសុំរកទំនិញឱ្យបានល្អដូចដើម ជួស កញ្ចប់ ឡាំង ដែលខូចខាត ដុះផ្សិតបាត់បង់ ឬព្រួសព្រាយ ព្រមទាំងចូលរួមដោះស្រាយបញ្ហាវិវាទពាក់ព័ន្ធនឹងទំនិញទាំងនេះ ។

៥- ជាភ្នាក់ងារកណ្តាលក្នុងការជួល ទិញ លក់ ប្រគល់ ទទួល កាន់កាប់ ស៊ីប្រ៊ាក់នាវា និងទាក់ទងនឹងការជួល ដឹក ផ្ទុក រើ បញ្ជូន និងផ្ទេរមកផ្នែងផ្ទុកទំនិញ ព្រមទាំងចុះកិច្ចសន្យាតាងនាមម្ចាស់នាវា ឬអ្នកជួលនាវាលើកិច្ចសន្យាទាំងនោះ ។

៦- សម្រួលការផ្គត់ផ្គង់ ការពិនិត្យអនាម័យនៅលើនាវា ធ្វើពាក្យសុំវិញ្ញាបនបត្រ ឬបញ្ជាក់ថ្នាំ សម្លាប់សត្វល្អិតបំពុលសត្វកណ្តុរនៅលើនាវា ។

៧- ត្រៀមកន្លែង រៀបចំទម្រង់ការស្វាគមន៍ និងអ្នកដំណើរ ឡើង ចុះនាវា ។

៨- សម្រួលការឲ្យនាវិកឡើងគោក ដើម្បីទាក់ទងការងារផ្សេងៗ ជាមួយ ភ្នាក់ងារមានសមត្ថកិច្ច ឬក្រសួងនានាធ្វើសច្ចកិច្ច ឬព្យាបាលជំងឺនៅមន្ទីរពេទ្យ ធ្វើមាតុភូមិនិវត្តន៍ ផ្លាស់ប្តូរនាវិកពីនាវាមួយទៅនាវាមួយផ្សេងទៀត ដែលអាចធ្វើដំណើរតាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ។

៩- សម្រួលការផ្គត់ផ្គង់ស្បៀងអាហារ ទឹកសាប ប្រេងឥន្ធនៈ កន្ទេល ភួយខ្នើយ ឬគ្រឿងទេស ប្រដាប់ផ្ទះបាយ គ្រឿងប្រើប្រាស់ សម្ភារៈ និងឧបករណ៍ផ្សេងៗ ដល់នាវាក្នុងករណីត្រូវការ ។

១០- ប្រមូល និងផ្ញើប្រាក់ឈ្នួលនាវា ក្រោយពេលសម្រួលក្នុងការដោះស្រាយប្រាក់ឈ្នួល ឬប្រាក់ពិន័យក្នុងការលើកដាក់ទំនិញ ។

១១- ចាត់ចែងជួយសង្គ្រោះនាវាក្នុងពេលមានគ្រោះថ្នាក់ ហើយជួយសម្របសម្រួលដោះស្រាយប្រាក់សំណង និងប្រាក់រង្វាន់នៃការជួយសង្គ្រោះនាវា ។

១២- សម្រួលទំនាក់ទំនងការងារ រវាងម្ចាស់នាវា និងកំពង់ផែ ម្ចាស់ទំនិញ ស្ថាប័នរដ្ឋក្នុងពេលនាវាស្ថិតនៅកំពង់ផែ ដើម្បីដោះស្រាយបញ្ហា និង សំណូមពរនានារបស់ម្ចាស់នាវា ហើយផ្តល់ព័ត៌មានអំពីសកម្មភាពនាវានៅកំពង់ផែ ។

១៣- ចាត់ចែងគ្រប់គ្រង កម្មករនៃផ្នែកលើកដាក់ ធ្វើការដឹកជញ្ជូនតាមផ្លូវទឹក គោក និង អាកាស បំពេញការកិច្ចជាភ្នាក់ងារប្រតិបត្តិការ ភ្នាក់ងារបញ្ជូនទំនិញ ភ្នាក់ងារការពារនាវា ។

១៤- ធ្វើការងារ ធានារ៉ាប់រង ធនាគារ និងគ្រប់គ្រងសណ្ឋាគារ សំរាប់ជួល ឲ្យម្ចាស់នាវា អ្នកជួលនាវា និងនាវិក ។

១៥- បន្តនិរន្តរភាពការកិច្ចម្ចាស់នាវា ឬអ្នកជួលនាវាឲ្យមានប្រសិទ្ធភាពជាមួយភាគីសាមី រួមមានចំណុចខាងក្រោមនេះ :

- ការចុះកិច្ចសន្យាអាចធ្វើតាមរយៈទូរលេខ ឬ តេឡិច
- លក្ខណៈសម្បត្តិនៃនាវា
- ពត៌មាននៃការមកដល់របស់នាវា

- ប្រាក់កក់នៅធនាគារ
- ផលការដឹកជញ្ជូនតាមផ្លូវសមុទ្រ ទន្លេ ។

មាត្រា ៣.- **កាំសាប** មានសិទ្ធិ :

- ទទួលខុសត្រូវ និងចាត់ចែងក្នុងការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់លើការងាររបស់ខ្លួន
- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចគ្នានឹងអាជីវករ
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឲ្យមានប្រសិទ្ធភាព និងមានការរីកចំរើន
- ក្នុងឋានៈជាស្ថាប័នសាធារណៈ **កាំសាប** ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

មាត្រា ៤.- លើកលែងតែបទប្បញ្ញត្តិផ្ទុយនេះ **កាំសាប** ត្រូវបង់ពន្ធអាករ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៥.- ដើមទុនដំបូងនៃ **កាំសាប** ត្រូវកំណត់ដោយបញ្ជីតុល្យការចាប់ផ្តើម ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ។

ពេលដែលអនុក្រឹត្យនេះ ចូលជាធរមាន **កាំសាប**ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៦.- បុគ្គលិករបស់ **កាំសាប** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២
## ការដឹកនាំ និង គ្រប់គ្រង

មាត្រា ៧.- **កាំសាប** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិពេញលេញ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ បទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាព ដូចខាងក្រោម :

- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ០១រូប ជាប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ០១រូប ជាសមាជិក
- តំណាងក្រសួងមហាផ្ទៃ ០១រូប ជាសមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម ០១រូប ជាសមាជិក

- តំណាងនិយោជិតរបស់ **គាំសាច** ០១រូប ជាសមាជិក
- អគ្គនាយក **គាំសាច** ០១រូប ជាសមាជិក

**មាត្រា ៨.-** សមាជិកក្រុមប្រឹក្សាភិបាល ជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរៈជនដែលមានអាយុ មិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ព្រមទាំងមានជំនាញ ខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលមានទណ្ឌកម្មកំរិតធ្ងន់ពី តុលាការឡើយ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរ ដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **គាំសាច** ។

**មាត្រា ៩.-** ក្រុមប្រឹក្សាមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **គាំសាច** ក្នុងការរៀបចំលើកិត ស្នាអរណីយកិច្ចការផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍**

១- ផ្តល់ការយល់ព្រមលើគំរោងសហគ្រាស ដូចចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃទៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការណ៍ ដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការ គណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **គាំសាច** ។

៤- សំរេចតាមសំណើរបស់អគ្គនាយកនូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **គាំសាច** ជាភាគីហត្ថលេខី ស្របតាមលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ។

៦- សំរេចបង្កើត បើក ឬបិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ **គាំសាច** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- កំណត់ថ្លៃឈ្នួលដែលពាក់ព័ន្ធ និងអាជីវកម្ម សេវា**គាំសាច** ។

**មាត្រា ១០.-** ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយតម្រូវការផលប្រយោជន៍ នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានបួននាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាត្រូវធ្វើការប្រជុំយ៉ាងតិច ១ដង ក្នុងរយៈពេល ០៣ខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ ដែលមានវ័យចំណាស់ជាងគេដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សា ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

របៀបវារៈ នៃការប្រជុំព្រមទាំងឯកសារពាក់ព័ន្ធទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមាជិកយ៉ាងតិចពាក់កណ្តាល ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំចាំបាច់ទាមទារកូរ៉ុមទេ ។

សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចក្លាយជាការបានលុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។បើសិនជាការបែកសំឡេងមានចំនួនស្មើគ្នា សំលេងរបស់ក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា ១១ .-** សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅអាជ្ញាធរអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋព្រមទាំងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ ក្នុងរវាង១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនេះ ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលនោះ។

**មាត្រា ១២.-** អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារជាប្រក្រតី និងត្រូវបានតែងតាំងសំរាប់អាណត្តិ ០៣ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាលបច្ចេកទេស ។

មាត្រា ១៣.- ក្រុមប្រឹក្សាភិបាល ប្រគល់ជូនអគ្គនាយកឲ្យទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល នូវអំណាចចាំបាច់សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

**ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកត្រូវ :**

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **កាំសាប** ។

២- ទទួលដឹកនាំ **កាំសាប** លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវា និងហិរញ្ញវត្ថុ ។

៣- តំណាង**កាំសាប** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល។

៤- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងមានសិទ្ធិបញ្ជាត្រួតត្រាបណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូប ដែលជានិយោជិតរបស់ **កាំសាប** ដោយគោរពតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាន និង តាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

តំណាងឲ្យ**កាំសាប** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់ តវ៉ាការពារក្ដីឲ្យ**កាំសាប** និងការប្ដឹងជំទាស់ផ្សេងៗ ។

មាត្រា ១៤.- លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៥.- ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយកាំសាប ត្រូវគោរពតាមបែបបទ និងនីតិវិធី ដែលកំណត់ ដោយច្បាប់ជាធរមាន ។

## ជំពូកទី ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៦.- **កាំសាប**កាន់កាប់គណនេយ្យរបស់ខ្លួន ឲ្យបានស្របតាមបទដ្ឋានគណនេយ្យកម្ពុជា និងតាម វិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃ ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃ ៣១ ខែធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ ៣០ ខែមិនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ដោយផ្អែកលើរបាយការណ៍នៃគណនេយ្យករជំនាញ ដែលមានមុខងារជាស្នងការគណនី ។

តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៧.-** ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់អាណត្តិ បីការិយបរិច្ឆេទ ។

ប្រាក់ការរបស់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវចំណាយក្នុងបន្ទុកសាជីវកម្មរបស់ **អាំសាប** ។

ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទ អំពីភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុរបស់ **អាំសាប** ។

បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីសហគ្រាសសាធារណៈ

ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាល បានតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨.-** រៀងរាល់ឆ្នាំមុនថ្ងៃ ០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោង ផែនការសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**គំរោងផែនការប្រចាំឆ្នាំ ត្រូវបញ្ជាក់នូវ :**

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សេចក្តីវិធីវិនិយោគនេះ ។

២- ថវិកាសកម្មភាពដំណើរការនៃសហគ្រាស ។

៣- ចំណែលម្អលគេវិភាគចរណ៍ ។

៤- លក្ខណៈវិនិច្ឆ័យសកម្មភាពវែងឆ្ងាយលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ ឆាំសាច ។

មាត្រា ១៩.- ធនធាននៃ ឆាំសាច មានជាអាទិ៍ :

- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ ឲ្យ (តុល្យការដំបូងនៅពេលបង្កើត)
- ប្រាក់ចំណូលផ្សេង ៗ ដែលប្រភពបានមកពីសកម្មភាពរបស់សហគ្រាស
- ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ឆាំសាច
- ប្រាក់ខ្ចីបុល និងប្រាក់អំណោយផ្សេង ៗ

មាត្រា ២០.- ចំណាយនៃ ឆាំសាច រួមមាន :

- ចំណាយប្រព្រឹត្តិសកម្មភាពដំណើរការ
- ចំណាយវិនិយោគ
- សងបំណុល
- ចំណាយផ្សេងៗ

មាត្រា ២១.- ឆាំសាច អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២២.- ជារៀងរាល់ឆ្នាំក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់ចំណេញដែល ឆាំសាច ទទួលបានពីការបូកទាត់តាមវិធានគណនេយ្យ ឆាំសាច មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៣.- រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៤

## ទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៤.- រយៈពេល ១៥ថ្ងៃយ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ឆាំសាច ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចមានខាងក្រោមនេះ :

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- តារាងផែនការរបស់សហគ្រាស ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ

- របាយការណ៍ស្តីពីសកម្មភាព ធុរកិច្ច និងគណនីគ្រប់គ្រងទាំងឡាយរបស់ គាំសាប
- របាយការណ៍របស់សវនការគណនី

**មាត្រា ២៥.-** ត្រូវបានដាក់ឲ្យនៅអមគាំសាបនូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមាន សិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុច នៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយ អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០ ទៅ ២៥ នៃច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអគ្គនាយកគាំសាបកម្ពុជានាវាចរ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

**ឃឹ តាំងលីម**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

★★★

# អនុក្រឹត្យលេខ ៨២ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១.-** ត្រូវបានអនុញ្ញាត ឲ្យផ្ទេរឥណទានថវិកា ចំនួន ១.៤០០លានរៀល (មួយពាន់ បួនរយលានរៀល) ពីជំពូក១០ (បៀវត្ស និងប្រាក់បំណាច់) មកជំពូក៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ចំនួន ៤០០លានរៀល (បួនរយលានរៀល) និងមកជំពូក៣១

(អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងសង្គម) ចំនួន ១.០០០លានរៀល របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

មាត្រា ២.- ឥណទានចែកក្នុងមាត្រា១ ខាងលើ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ សំរាប់ :

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ ចំនួន ៣០០.០០០.០០០រៀល
- អាជ្ញាធរប្រេងកាតជាតិកម្ពុជា ចំនួន ១០០.០០០.០០០រៀល
- អាហារូបករណ៍ផ្សេងៗ ចំនួន ២៥៩.៤០០.០០០រៀល
- ទូទាត់ចំណាយលើគម្រោងកាកសំណល់ ចំនួន ៧៤០.៦០០.០០០រៀល

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** ជូនលោកឧត្តម Mr. ISSEI INOUE ដែលបានធ្វើអំណោយជាអាគារសិក្សា មួយខ្នង មាន ០៥បន្ទប់ រួមទាំងសម្ភារៈសិក្សា ជូនសាលាបឋមសិក្សា អ៊ីនូអេ ត្រពើង ក្នុងឃុំរាមអណ្ដើក ស្រុកគីរីវង់ ខេត្តតាកែវ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

ភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៨៧ អនក្រ.តត
## ស្ដីពីការតែងតាំងសមាសភាពតំណាងប្រមុខរាជរដ្ឋាភិបាល ក្នុងក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃកម្ពុជា
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិ នៃកម្ពុជា

**សំរេច**

**មាត្រា ១.-** ត្រូវបានតែងតាំងឯកឧត្តម **នួន ព័ន្ធមុនីរ័ត្ន** ជាសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា តំណាងឲ្យប្រមុខរាជរដ្ឋាភិបាល ជំនួសលោកជំទាវ **ស៊ិន សិរី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៤៨៨ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១.-** ត្រូវបានតែងតាំងលោក ឆេង ឫទ្ធី ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស និងជាឧត្តមមន្ត្រីសេដ្ឋកិច្ចកម្ពុជា សំរាប់អាស៊ាន បន្ថែមលើមុខងារបច្ចុប្បន្ន នៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៨៩ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១.-** ត្រូវបានតែងតាំងលោក អ៊ុយ សម្បត្តិ ជាឧត្តមមន្ត្រី សេដ្ឋកិច្ចកម្ពុជា តាំងរាប់អាណាខាន បន្ថែមលើមុខងារបច្ចុប្បន្ន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៤៩០ អនក្រ .តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១.-** តែងតាំងលោក ឡុង ផល ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការព្រំដែន មានឋានៈស្មើ អគ្គនាយករង ។

មាត្រា ២.- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៩១ អនក្រ.តត
## ស្តីពីការដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញ អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យមន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១.- អនុញ្ញាតឲ្យលោកជំទាវ ម៉ូ រ៉ាស៊ី កើតនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៣៩ បច្ចុប្បន្នជាមន្ត្រីក្របខ័ណ្ឌក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចូលនិវត្តន៍ក្នុងតំណែងមុខងារសាធារណៈ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៩២ អនក្រ .តត
## ស្តីពីការតែងតាំងប្រធានអន្តនាយកចំការកៅស៊ូ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១៣,១៤, ១៥, ១៦, ១៧, ១៨, ១៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូមេមត់ ចំការកៅស៊ូក្រែក ចំការកៅស៊ូពាមជាំង ចំការកៅស៊ូបឹងកេត ចំការកៅស៊ូចំការអណ្តូង និងចំការកៅស៊ូស្នួល ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

មាត្រា ១.- ត្រូវបានតែងតាំងជាប្រធានអគ្គនាយក តាមបណ្តាច់ការកៅស៊ូទាំង ០៧ ដែលជាគ្រឹះស្ថានសាធារណៈ មានលក្ខណៈសេដ្ឋកិច្ច ដែលមានរាយនាមដូចខាងក្រោម ៖

១- លោក ណា ម៉ារឌី ជាប្រធានអគ្គនាយកចំការកៅស៊ូមេមត់
២- លោក ម៉ក់ គីមហុង ជាប្រធានអគ្គនាយកចំការកៅស៊ូជុប
៣- លោក សៀក ពិសិដ្ឋ ជាប្រធានអគ្គនាយកចំការកៅស៊ូក្រែក
៤- លោក ម៉ែន ស៊ីផាន់ ជាប្រធានអគ្គនាយកចំការកៅស៊ូពាមជាំង
៥- លោក ស៊ឹម វណ្ណា ជាប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត
៦- លោក ចាន់ ហ៊ិត ជាប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង
៧- លោក ហេង សារ៉ាត ជាប្រធានអគ្គនាយកចំការកៅស៊ូស្នួល

មាត្រា ២.- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សាការដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៩៣ អនក្រ.តត

## ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១៣,១៤, ១៥, ១៦, ១៧, ១៨, ១៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូមេមត់ ចំការកៅស៊ូក្រែក ចំការកៅស៊ូពាមជាំង ចំការកៅស៊ូបឹងកេត ចំការកៅស៊ូចំការអណ្តូង និងចំការកៅស៊ូស្នួលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១.-** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូទាំង៧ ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលមានរាយនាមដូចខាងក្រោម ៖

**ក-សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូមេមត់ :**

| | | | |
|---|---|---|---|
